វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

**ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង**

*Working Together for Positive Change*

# កំណត់ហេតុ
# កិច្ចប្រជុំសមាជិកប្រចាំឆ្នាំ



ថ្ងៃ ព្រហស្បតិ៍ ទី៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ០៨ ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

ទីកន្លែង: មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)
អាគារ IFL, មហាវិថីសហពន្ធ័រុស្ស៊ី, រាជធានីភ្នំពេញ

# កំណត់ហេតុ
# កិច្ចប្រជុំសមាជិកប្រចាំត្រីមាស
## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ថ្ងៃ ព្រហស្បតិ៍ ទី៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ០៨ ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

ទីកន្លែងៈ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)
អាគារ IFL, មហាវិថីសហពន្ធ័រុស្ស៊ី, រាជធានីភ្នំពេញ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិកប្រចាំត្រីមាសជាលើកទីមួយរបស់ខ្លួនក្នុងឆ្នាំ២០១៣ ដែលបានប្រព្រឹត្តិទៅនៅថ្ងៃ ព្រហស្បតិ៍ ទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ នៅសាលប្រជុំនៃមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)។ កិច្ចប្រជុំបានចាប់ផ្តើម នៅម៉ោង ០៨ ព្រឹក និងបញ្ចប់នៅម៉ោង ១២ ថ្ងៃត្រង់ ដែលមានអ្នកចូលរួមសរុបចំនួន ១៥៤ នាក់ (ក្នុងនោះមានស្ត្រី ៤៤ នាក់) មកពីខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ដែលជាតំណាងមកពីអង្គការសមាជិក តំណាងអង្គការសង្គមស៊ីវិល និងសមាជិកបណ្តាញ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

១. មតិស្វាគមន៍របស់ប្រធានអង្គប្រជុំ

ជាកិច្ចចាប់ផ្តើម **លោកស្រី ប៉ុក បញ្ញាវិចិត្រ** ប្រធានអង្គប្រជុំ, នាយិកាប្រតិបត្តិនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ, និងជា ប្រធានគណៈកម្មាធិការគ្រប់គ្រង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានស្វាគមន៍ដល់សមាជិក-សមាជិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលបានចូលរួមកិច្ចប្រជុំដំបូងក្នុងឆ្នាំ២០១៣។ មានសមាជិកចំនួន ៩០ និង អង្គកាសមាជិកបណ្តាញចំនួនជាង ៣០០ បេសកកម្មចម្បងដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ដែលត្រូវរំលោភសិទ្ធិលើបញ្ហាបរិស្ថាន បញ្ហាអភិវឌ្ឍន៍ បញ្ហាធនធានធម្មជាតិ ដែលទាក់ទងនឹងជីវភាពរស់នៅ ពិសេស បញ្ហាដីធ្លី។ កន្លងមកវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សម្រេចបាននូវសមិទ្ធិផលសំខាន់ៗមួយចំនួន ដូចជា រដ្ឋាភិបាលបានពន្យាពេលចំពោះការផ្តល់ដីសម្បទានសេដ្ឋកិច្ច បានផ្តល់ធាតុចូលជាច្រើនក្នុងគោលនយោបាយ និងច្បាប់ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) បានបំពេញតួនាទីយ៉ាងល្អប្រសើរក្នុងការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងការរៀបចំវេទិកាកសិករ វេទិកាប្រជាជនអាស៊ាន និងវេទិកាផ្សេងៗទៀត។ ទោះជាយ៉ាងណា ក៏មានបញ្ហារាំងស្ទះមួយចំនួន ដូចជា ការចូលរួមចំណែកជាមួយនឹងរដ្ឋាភិបាលដោយសារបញ្ហារសើប ខ្វះព័ត៌មាន សម្រាប់ការបោះពុម្ពផ្សាយ ឧទាហរណ៍ ច្បាប់ចរិកាជាតិ ការលំបាកក្នុងការទាក់ទាញឲ្យមានការចូលរួមពីសមាជិក។ លោកស្រីបានលើកទឹកចិត្តដល់សមាជិកទាំងអស់ ចូលរួមគាំទ្រឲ្យបានច្រើនដើម្បីជម្រុញការងារឲ្យមានប្រសិទ្ធភាព។ លោកស្រីក៏បានសំណូមពរឲ្យអ្នកចូលរួមទាំងអស់ពិភាក្សាលើបញ្ហាស្តីពីការប្រែប្រួលអាកាសធាតុ ការចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រង របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

២. ការអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុនៅកម្ពុជា និង លទ្ធផលនៃសន្និសីទលើកទី ១៨ នៃបណ្តាភាគីជាសមាជិក អនុសញ្ញា ក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នាទីក្រុងដូហា ប្រទេសកាតា

**លោក អ៊ុក ណាវ៉ាន់** អគ្គនាយករងនៃក្រសួងបរិស្ថាន បានធ្វើបង្ហាញនូវការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបនឹងបញ្ហាការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងលទ្ធផលនៃសន្និសីទលើកទី ១៨ នៃបណ្តាភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នាទីក្រុងដូហា ប្រទេសកាតា។ ចំពោះបញ្ហាប្រែប្រួលអាកាសធាតុ ប្រទេសកម្ពុជាបានចុះហត្ថលេខាចូលជាសមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅខែធ្នូ ឆ្នាំ១៩៩៥ និងបានចុះហត្ថលេខាចូលជាសមាជិកពិធីសារក្យូតូ ក្នុងខែមេសា ឆ្នាំ២០០២ ក្រោយមកទៀតក្នុងខែមករា ឆ្នាំ២០១០ បានគាំទ្រកិច្ចព្រមព្រៀងទីក្រុងកូប៉េនហាក។ ជារៀងរាល់ឆ្នាំ គណៈប្រតិភូត្រូវបានបញ្ជូនទៅចូលរួមក្នុងកិច្ចប្រជុំ។ ទោះបីជាប្រទេសកម្ពុជាយើងមិនមែនជាប្រទេសដែលរួមចំណែកក្នុងការប្រែប្រួលអាកាសធាតុ ក៏យើងគិតគូពីបញ្ហាប្រែប្រួលអាកាសធាតុដែរ។ រាជរដ្ឋាភិបាលយើងទទួលបានចំណេញច្រើនដោយយើងមានឈ្មោះនៅលើឆាកអន្តរជាតិ តាមរយៈការចូលរួមដោះស្រាយបញ្ហានេះ។ ដោយសារតែយើងជាប្រទេសសមាជិកក្របខណ្ឌសហប្រជាជាតិ គេតម្រូវឲ្យយើងរៀបចំរបាយការណ៍ជាតិសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ ដែលរួមមាន ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ កម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការផ្ទេរបច្ចេកវិជ្ជា កិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ ការស្រាវជ្រាវ ការកសាងសមត្ថភាព ការអប់រំផ្សព្វផ្សាយហិរញ្ញប្បទាន។ របាយការណ៍ជាតិលើកទី១ បានដាក់ជូនក្នុងកិច្ចប្រជុំលើកទី៨ ក្នុងឆ្នាំ២០០២។ បច្ចុប្បន្ន យើងកំពុងរៀបចំបញ្ចប់របាយការណ៍ជាតិលើកទី២។ ស្ថាប័នជាតិពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើង ដែលមានស្ថាប័នជាតិពាក់ព័ន្ធចំនួន ២០ ដែលមានក្រសួងបរិស្ថានជាស្ថាប័នបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ។ ក្នុងនោះការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា ត្រូវបានបង្កើតឡើង នៅខែមិថុនា ឆ្នាំ២០០៣ និងបានតម្លើងជានាយកដ្ឋានប្រែប្រួលអាកាសធាតុ នៅខែតុលា ឆ្នាំ២០០៩។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានបង្កើតឡើង ក្នុងខែមេសា ឆ្នាំ២០០៦ ដែលមានភារកិច្ចរៀបចំ សម្របសម្រួល និងតាមដាន ពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ គណៈកម្មាធិការនេះត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទទួលធ្វើជាប្រធានកិត្តិយសនៃគណៈកម្មាធិការនេះ នៅខែតុលា ឆ្នាំ២០០៩។ នៅក្នុងគណៈកម្មាធិការគ្រប់គ្រងស្តីពីការប្រែប្រួលអាកាសធាតុ មាននាយកដ្ឋានប្រែប្រួលអាកាសធាតុ ជាលេខាធិការដ្ឋាន ក្នុងនោះមានក្រុមការងារអន្តរក្រសួង ផ្នែកថាមពល ក្រុមការងារអន្តរក្រសួងផ្នែកព្រៃឈើ ជាដើម។ ប្រទេសកម្ពុជាបានធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ សម្រាប់ឆ្នាំ១៩៩៤ ការវិភាគការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពល និងដឹកជញ្ជូន កសិកម្ម ការប្រើប្រាស់ដី និងព្រៃឈើ ការវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការវិភាគគោនយោបាយ ដែលឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ការអង្កេតគ្រួសារជនបទស្តីពីភាពងាយរងគ្រោះ និង បន្សាំនឹងការប្រែប្រួលអាកាសធាតុ ស្ថានភាព និងការការវាយតម្លៃថាមពលនិរន្តរភាពនៅកម្ពុជា សម្រាប់យន្តការអភិវឌ្ឍន៍ស្អាត ការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត មគ្គុទេសក៏ស្តីពីយន្តការអភិវឌ្ឍន៍ស្អាតសម្រាប់ប្រទេសកម្ពុជា ពីសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅជាគំរោងយន្តការអភិវឌ្ឍន៍ស្អាត ដែលអាចសំរេចបាន។ កន្លងមក យើងបានអនុវត្តគំរោង និងគៀងគរធនធាន ក្នុងនោះមាន គម្រោងយន្តការអភិវឌ្ឍន៍ស្អាត គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ទីផ្សារកាបូនស្ម័គ្រចិត្ត កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (២០០៦) គម្រោងលើកកំពស់ការគ្រប់គ្រងធនធានទឹក និងទម្លាប់ប្រតិបត្តិកសិកម្ម គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុៈ មូលនិធិប្រែប្រួលអាកាសធាតុ (៨,៩លានដុល្លារ) និងកម្មវិធីសាកល្បងសម្រាប់ភាពធន់ទ្រាំនឹងអាកាសធាតុ (ធនាគារពិភពលោក)។ ក្រសួងបរិស្ថាន បានសហការជាមួយក្រសួងផែនការ និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន

កម្មឆ្នាំ២០០៩-២០១៣។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដែលដឹកនាំដោយក្រសួងបរិស្ថាន បានសហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ៩ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ដែលគ្របដណ្តប់លើវិស័យអាទិភាពចំនួន ១៦ របស់រាជរដ្ឋាភិបាល។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រអប់រំ និងផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ។ លោកក៏បានធ្វើការបង្ហាញនូវលទ្ធ-ផលកិច្ចប្រជុំកំពូលលើកទី១៨ នៃបណ្តាភាគីជាសមាជិកអនុសញ្ញា នៅទីក្រុងដូហា ប្រទេសកាតា ក្នុងនោះមាន លទ្ធ-ផលទី១ ការឯកភាពដោយអនុនោមតាមផែនការសកម្មភាពទីក្រុងបាលី ផ្អែកលើចក្ខុវិស័យសម្រាប់សកម្មភាពសហប្រតិបត្តិការរយៈពេលវែង ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តាមរយៈសកម្មភាពជាតិ/អន្តរជាតិ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ លើកកម្ពស់សកម្មភាពបន្សាំ ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា ការបែងចែកធនធានហិរញ្ញវត្ថុ និងវិនិយោគ ការកសាងសមត្ថភាពដើម្បីគាំទ្រសកម្មភាព កាត់បន្ថយនិងបន្សាំ ព្រមទាំងកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យា។ លទ្ធផលទី២ កំនត់សកម្មភាពបន្ថែមសម្រាប់សកម្មភាពការងារក្នុងឆ្នាំ២០១៤ ដើម្បីធានាដល់កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយឧស្ម័ន ដោយលទ្ធភាពខ្ពស់បំផុត ក្រោមអនុសញ្ញា និងសម្រេចក្រុមការងារពិសេសនៃទីក្រុងឌូបាន នឹងពិចារណាបណ្តាធាតុ សម្រាប់ឯកសារចរចា ដោយធ្វើការងារជាបន្ទាន់ និងវិធានការផ្លូវច្បាប់នានា ក្រោមអនុសញ្ញាឲ្យបានមុនកិច្ចប្រជុំនៃសន្និសីទលើកទី២០ ក្នុងឆ្នាំ២០១៤។ លទ្ធផលទី៣ ប្រទេសឧស្សាហកម្មបានយល់ព្រមបន្តការប្តេជ្ញាចិត្តលើកទី២ ក្រោមពិធីសារក្យូតូ ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ ដើម្បីកំណត់គោលដៅសេដ្ឋកិច្ច ជាមួយនឹងការកំនត់បរិមាណការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឬបរិមាណឧស្ម័នផ្ទះកញ្ចក់ ត្រូវកាត់បន្ថយសម្រាប់ពិនិត្យឡើងវិញ។ ប្រទេសអាល្លឺម៉ង់ និងចក្រភពអង់គ្លេស បានប្រកាសផ្តល់ថវិកា ៧០លានអឺរ៉ូ ដល់ប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់កម្មវិធី និង គម្រោង NAMA។ លទ្ធផលទី ៤ សម្រេចលើសេចក្តីព្រាងវិធីសាស្ត្រឆ្លើយតបការខូចខាត និងការបាត់បង់ទាក់ទងនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសបណ្តាប្រទេសងាយគ្រោះថ្នាក់ដោយសារការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់សមត្ថភាពបន្សាំ។ លទ្ធផលទី ៥ សម្រេចសេចក្តីព្រាងផែនការបន្សាំថ្នាក់ជាតិ ដោយផ្តួចផ្តើមគោលការណ៍ណែនាំសម្រាប់បង្កើតផែនការបន្សាំ ដោយបណ្តាភាគី មានប្រទេសអភិវឌ្ឍន៍តិចតួច ដែលបានអនុម័តសម្រេច។ សម្រេចផ្តល់ការណែនាំចំពោះមូលនិធិបរិស្ថានពិភពលោក អង្គភាពប្រតិបត្តិនៃយន្តការហិរញ្ញវត្ថុ សម្រាប់ប្រតិបត្តិមូលនិធិប្រទេសមានការអភិវឌ្ឍនតិចតួច ដើម្បីជម្រុញសកម្មភាពសម្រាប់ដំណើរការនៃការរៀបចំផែនការបន្សាំថ្នាក់ជាតិ។ លទ្ធផលទី៦ សម្រេចសេចក្តីព្រាង ការងារគណៈកម្មាធិការបន្សាំ ដោយចាត់បញ្ជូនសមាជិកតំណាង ក្រុមប្រទេសក្នុងដំណាច់ឆ្នាំ ២០១២ និងរៀបចំប្រជុំដំបូងរបស់ខ្លួនក្នុងឆ្នាំ ២០១៥ សម្រាប់សមាជិកបំពេញការងាររយៈពេល ២ឆ្នាំ និងរៀបចំប្រជុំដំបូងក្នុងឆ្នាំ ២០១៦ សម្រាប់សមាជិកបំពេញការងារ ៣ឆ្នាំ។ លទ្ធផលទី៧ សម្រេចការរៀបចំរវាងភាគីជាសមាជិកនៃអនុសញ្ញា និងមូលនិធិអាកាសធាតុបៃតង ដែលបានសម្រេចក្នុងសន្និសីទទី ១៦ និង១៧ កន្លងទៅនេះ សម្រាប់ប្រតិបត្តិយន្តការហិរញ្ញវត្ថុ និងក្រុមប្រឹក្សានៃអនុសញ្ញាក្នុងកិច្ចប្រជុំលើកទី១៩ ខាងមុខ។ លទ្ធផលទី៨ សម្រេចដូហា កម្មវិធីអនុវត្តមាត្រាទី៦ នៃអនុសញ្ញា រយៈពេល ៨ឆ្នាំ ដើម្បីកសាងសមត្ថភាពលើកកម្ពស់ការយល់ដឹង ក្នុងគោលបំណងជម្រុញការចូលរួមរបស់សាធារណៈជន ក្នុងការធ្វើសេចក្តីសម្រេចលើការងារប្រែប្រួលអាកាសធាតុ។ សម្រេចធ្វើការពិនិត្យមើលកម្មវិធីអនុវត្តឡើងវិញ នៅឆ្នាំ២០២០ ដោយពិនិត្យមើលលើដំណើរការអនុវត្តឆ្នាំ២០១៦។ លទ្ធផលទី៩ ប្រទេសអភិវឌ្ឍន៍បានសន្យាបន្តគៀងគរហិរញ្ញវត្ថុរយៈពេលវែង ដល់ប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ១០០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ គិតត្រឹមឆ្នាំ២០២០។ ក្នុងមួយឆ្នាំ ប្រទេសអភិវឌ្ឍន៍នឹងផ្តល់ថវិកាយ៉ាងតិច ១០ពាន់ដុល្លា ចន្លោះ ឆ្នាំ២០១៣-២០១៥ ក្នុងនោះរួមមាន ប្រទេសអាល្លឺម៉ង់ ចក្រភពអង់គ្លេស បារាំង ដាណឺម៉ាក ស៊ុយអ៊ែត និងសហគមន៍អឺរ៉ុប បានប្រកាសនឹងផ្តល់ហិរញ្ញប្បទានប្រមាណ ៦ពាន់លានដុល្លារ រហូតដល់ឆ្នាំ២០១៥។ លទ្ធផលទី១០ សម្រេចសេចក្តីព្រាងសន្និសីទលើកទី១៩ នឹងត្រូវ

រៀបចំប្រារព្ធឡើងនៅទីក្រុងវ៉ាសាវី ប្រទេសប៉ូឡូញ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយអនុលោមតាមអគ្គលេខាធិការសភាសហប្រជាជាតិ។

៣. ទស្សនៈរបស់អង្គការសង្គមស៊ីវិល ចំពោះលទ្ធផលនៃសន្និសីទលើកទី ១៨ នៃបណ្តាភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នាទីក្រុង ដូហា ប្រទេសកាតា

**លោក ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានធ្វើបទបង្ហាញលើចំណុចសំខាន់ ៤ ទាក់ទងនឹង មុនកិច្ចប្រជុំ COP18 ការស្នើសុំ និងយល់ព្រមលើ COP18 សន្និដ្ឋាន និងសំណូមពរ។ លោកក៏បានលើកឡើងនូវហេតុផលសំខាន់ៗមួយចំនួន ទាក់ទងនឹងការចរចាររបស់សង្គមស៊ីវិល រួមមាន ការយល់ដឹងអំពីការចរចារមានកម្រិត សង្គមស៊ីវិលមួយចំនួនមិនយល់អំពីការចរចារ និងចាំបាច់ត្រូវលើកឡើងកង្វល់របស់សហគមន៍ក្នុងថ្នាក់អន្តរជាតិ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បណ្តាញប្រែប្រួលអាកាសធាតុ DCA/CA CCIM ជាមួយនឹងការគាំទ្រពីសមាជិកបណ្តាញ បានរៀបចំសន្និសីទកាសែត កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១២ សេចក្តីថ្លែងការណ៍ត្រូវបានចែកជូនទៅសមាជិកបណ្តាញ NGOF និង CCCN សេចក្តីថ្លែងការណ៍ត្រូវបានចេញផ្សាយដោយកាសែតដឹខេមបូខាដេលី នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នា២០១២។ នៅក្នុងកិច្ចចរចារនេះ ការចូលរួមជាមួយនិងអង្គការអន្តរជាតិ ដូចជា CAN International, Southern Voice Program, ACT Alliance ផងដែរ។ ឯកសារគោលជំហររបស់អង្គការសង្គមស៊ីវិលកម្ពុជា ត្រូវបានចែកជូនបណ្តាញអង្គការអន្តរជាតិ គណៈប្រតិភូរបស់ប្រទេសនីមួយៗ អ្នកចរចារ និងបណ្តាញអង្គការសមាជិក ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយជាតិ និង អន្តរជាតិ។ គោលជំហររបស់សង្គមស៊ីវិលដែលបានលើកឡើងក្នុងសន្និសីទ បានផ្តោតលើការបន្សាំ កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ កម្មវិធី REDD+ បច្ចេកវិទ្យា និងការពង្រឹងសមត្ថភាព។ ចំពោះការបន្សាំ សង្គមស៊ីវិលបានគាំទ្រឲ្យមានផែនការបន្សាំជាតិ (NAPs) ហិរញ្ញប្បទានសម្រាប់ការបន្សាំ និងការកាត់បន្ថយគួរតែស្មើគ្នា គាំទ្រកិច្ចព្រមព្រៀងទីក្រុងឌូបាន (ADP) គាំទ្រឲ្យមានក្របខណ្ឌទូទាត់សំណងពីការបាត់បង់និងការខូចខាត និងមានភាពងាយទទួលបានហិរញ្ញប្បទានសម្រាប់ការបន្សាំ។ សន្និសីទីលើកទី ១៨ នេះ បានព្រមព្រៀងលើគោលជំហរ លើគោលការណ៍ជួយដល់ប្រទេសអភិវឌ្ឍន៍ រៀបចំផែនការបន្សាំជាតិ (National Adaptation Plans) និងការដាក់បញ្ចូលទស្សនៈការបាត់បង់ និងការខូចខាតដែលជាជំហានដំបូងនៃ UNFCCC។ គោលជំហរចំពោះការកាត់បន្ថយ រួមមាន រក្សាកំណើនសីតុណ្ហភាពបរិយាកាសមធ្យមឲ្យនៅក្រោម ១,៥ អង្សារសេ គាំទ្រចំពោះការបន្តពិធីសារក្យូតូ ជំហានទី២ (ខែមករា ឆ្នាំ២០១៣ ដល់ខែធ្នូ ឆ្នាំ២០១៧) ប្រទេសអភិវឌ្ឍន៍កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ឲ្យបាន ៤០ភាគរយ នៅឆ្នាំ២០២០ គាំទ្រការអនុវត្ត NAMA និង MRV សម្រាប់ភាគីសមាជិកអនុសញ្ញា តែប្រទេសអភិវឌ្ឍន៍ត្រូវមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ធនធាន ការពង្រឹងសមត្ថភាព និងកម្មសិទ្ធិបញ្ញា។ សន្និសីទបានព្រមព្រៀងលើពិធីសារចូលរួមកាត់បន្ថយ ១៥ភាគរយ នៃឧស្ម័នផ្ទះកញ្ចក់សកលលោក ប្រទេសអភិវឌ្ឍន៍តិចតួច ព្រមអនុវត្ត NAMAs និង MRV ក្នុងបរិបទ "ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព" តែទាមទារឲ្យប្រទេសអភិវឌ្ឍន៍ គាំទ្រ ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងពង្រឹងសមត្ថភាព ហើយប្រទេសអភិវឌ្ឍន៍ឯកភាពអនុវត្ត NAMAs និង MRV ក្នុងបរិបទគោរពគោលការណ៍ UNFCCC គឺ "ទទួលខុសត្រូវរួម ប៉ុន្តែក្នុងកំរិតផ្សេងៗគ្នា"។ គោលជំហររបស់សង្គមស៊ីវិល លើកម្មវិធី REDD+ សូមឲ្យមានយន្តការច្បាស់លាស់អំពីមូលនិធិគាំទ្រ សម្រាប់ការអនុវត្តកម្មវិធី មានមូលនិធិរយៈពេលខ្លី និងបន្ថែម សម្រាប់ REDD+ ការអនុវត្តគម្រោង REDD+ ថ្នាក់ជាតិ គួរគោរពតាមគោលការណ៍ព្រមព្រៀងដោយសេរីជាមុន និង ដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC)។ សន្និសីទនេះពុំសូវខ្វះខ្នែងឲ្យកម្មវិធី REDD+ នេះ ដំណើរការនោះទេ។ ជំហរចំពោះហិរញ្ញប្បទាន សង្គមស៊ីវិលស្នើឲ្យមានការគៀងគរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុរហូតដល់ ១០០កោដិដុល្លារ គិតត្រឹមឆ្នាំ២០២០ ដែលបានប្តេជ្ញាក្នុងកិច្ចព្រមព្រៀងទីក្រុងកូប៉ែនហាក ប្រទេសដាណឺម៉ាក ហិរញ្ញប្បទានបន្ថែម អាចប្រើប្រាស់បាន និងមាននិរន្តរភាព សម្រាប់ការកាត់បន្ថយ និងបន្សាំ

ឲ្យបានស្មើភាពគ្នា ហិរញ្ញប្បទានជាជំនួយមិនមែនកម្ចី ចាប់ផ្តើមផ្តល់ហិរញ្ញប្បទានចំនួន ៣០លានដុល្លារ និងសង្គមស៊ីវិលគប្បីជាតួអង្គសំខាន់ក្នុងការពិនិត្យមើលថវិកានេះ។ ចំពោះគោលជំហរបច្ចេកវិទ្យា សង្គមស៊ីវិលគាំទ្រឲ្យមានគណៈកម្មាធិការប្រតិបត្តិការបច្ចេកវិទ្យា (Technology Executive Committees) គាំទ្រឲ្យមានមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ និងបណ្តាញ (Climate Technology Center and Network) និងគាំទ្រឲ្យមានការវាយតម្លៃតម្រូវការបច្ចេកវិទ្យា (Technology Need Asessment)។ សន្និសីទបានសម្រេច និងឯកភាពតាមចំនុចទាំងបី។ គោលជំហរចុងក្រោយរបស់សង្គមស៊ីវិល ចំពោះការពង្រឹងសមត្ថភាព សូមឲ្យរាប់បញ្ចូលជាអន្តរវិស័យ ដូចជា កសិកម្ម ព្រៃឈើ ជលផល ធនធានទឹក ថាមពល សុខភាព ផែនការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ជាដើម។ ពង្រឹងសមត្ថភាពស្រាវជ្រាវបែបវិទ្យាសាស្ត្រឲ្យបានគ្រប់ប្រទេស និងការលើកកម្ពស់យេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ។ សំណើចំពោះការពង្រឹងសមត្ថភាព សន្និសីទមិនជម្រុញឲ្យមានដំណើរការទេ។ ជារួម សន្និសីទកំពូលលើកទី១៨ នៅដូហា មិនសូវមានដំណើរការច្រើនទេ ក្នុងនោះ ប្រទេសកំពុងអភិវឌ្ឍន៍តិចតួច និងក្នុងឧបសម្ព័ន១ មានទស្សនៈ និងគោលគំនិត ព្រមទាំងការទទួលខុសត្រូវផ្សេងគ្នា។ បញ្ហាជាច្រើនពាក់ព័ន្ធនឹងឆន្ទៈនយោបាយ សេដ្ឋកិច្ច ការប្រកួតប្រជែងទីផ្សារ បច្ចេកទេស ធនធាន ហិរញ្ញវត្ថុ ជាដើម។ ប្រទេសអភិវឌ្ឍន៍មួយចំនួនបានព្យាយាមបង្អាក់ដំណើរការចរចារ។ មហិច្ឆតាកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់មានកម្រិតទាប ឧទាហរណ៍ សហគមន៍អឺរ៉ុបនឹងកាត់បន្ថយការបញ្ចេញប្រមាណ ២០ភាគរយ ដែលតិចជាងការប្តេជ្ញាចិត្តបច្ចុប្បន្ន។ ប្រទេសជប៉ុន រុស្ស៊ី កាណាដា និងញូវហ្សេលែន បានដកខ្លួនមិនចូលរួមក្នុងពិធីសារក្យូតូ ជំហានទី២។ សង្គមស៊ីវិលបាន សំណូមពរ ជូនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរតែមានការសហការយ៉ាងពេញលេញ ក្នុងការចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ព្រមទាំងការចរចារអន្តរជាតិ។ រដ្ឋាភិបាលគួរផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល ចូលរួមដំណើរការពិភាក្សាស្តីពីការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ NAMAs មានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ទទួលបានមូលនិធិបន្ថែម។ សង្គមស៊ីវិលគាំទ្ររដ្ឋាភិបាលក្នុងការរៀបចំផែនការបន្សាំជាតិ ពង្រឹងសមត្ថភាពចរចារបន្ថែម។ ហិរញ្ញប្បទានសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុគួរតែជំនួយឥតសំណង មិនមែនជាកម្ចីនោះទេ។

### ៨. បទពិសោធន៏នៃការអនុវត្តន៏កម្មវិធីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

**លោក សុខ សាខន** អ្នកសម្របសម្រួលនៃអង្គការការីតាសកម្ពុជា បានបង្ហាញថា អង្គការការីតាស បង្កើតឡើងវិញក្នុងខែមិថុនា ឆ្នាំ១៩៩០ កំពុងអនុវត្តការងារក្នុងតំបន់គោលដៅ ១០ ខេត្ត-ក្រុង និង មានកម្មវិធីសំខាន់ៗ ៥ រួមមានកម្មវិធីពង្រឹងសិទ្ធិអំណាចសហគមន៍ កម្មវិធីលើកកម្ពស់សន្តិសុខស្បៀង និងអភិវឌ្ឍន៍ជីវភាពរស់នៅប្រកបដោយនិរន្តរភាព កម្មវិធីអភិវឌ្ឍន៍សុខភាពសហគមន៍ កម្មវិធីថែទាំអ្នកផ្ទុកមេរោគអេដស៍ កម្មវិធីថែទាំ និងផ្តល់ជំនាញ ព្រមទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដល់អ្នកទោស កម្មវិធីមជ្ឈមណ្ឌលសម្រាប់សុខភាពផ្លូវចិត្តរបស់កុមារ និងយុវជន កម្មវិធីបង្ការថែទាំភ្នែក កម្មវិធីលើកកម្ពស់សិទ្ធិជាមូលដ្ឋាន យេនឌ័រ ការប្រឆាំងការជួញដូរស្ត្រី និងកុមារ កម្មវិធីបណ្តុះបណ្តាលជំនាញសម្រាប់យុវជន និងកម្មវិធីឆ្លើយតបនឹងគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីលើកកម្ពស់សន្តិសុខស្បៀងនៅសហគមន៍ មានសកម្មភាពបង្កើតជង្រុកស្រូវ ផលិតកម្មស្រូវ សួនបន្លែគ្រួសារ ចិញ្ចឹមសត្វ បង្កើនប្រាក់ចំណូល និងសន្សំប្រាក់។ ជំនាញបច្ចេកទេសកសិកម្ម កសិដ្ឋានបង្ហាញ ផលិតជីសរីរាង្គ ផលិតជីកំប៉ុស្តិ៍រឹង និងរាវ ចិញ្ចឹមសត្វ និងចិញ្ចឹមត្រី។ ការស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចៈ ប្រឡាយ ស្រះ អណ្តូងស្ថានីយបូមទឹក ពិនិត្យទំនប់និងទ្វារទឹក សាងសង់និងជួសជុលលូរ សាងសង់និងជួសជុលផ្លូវ សាងសង់និងជួសជុលស្ពាន។ ទឹកស្អាត និងអនាម័យៈ សាងសង់អណ្តូង/ស្នប់ដៃ ការអប់រំសុខភាព និងអនាម័យ។ ការកាត់បន្ថយហានិភ័យទឹកជំនន់ និងបន្សាំនៅកម្រិតសហគមន៍ៈ ប្រជាជនសាងសង់ផ្ទះលើកខ្ពស់ និងខ្ពស់ជាងកំពស់ទឹកជំនន់ កន្លែងសុវត្ថិភាពតាមគ្រួសារ ការផ្លាស់ប្តូរដំណាំ ការការពារ និងត្រៀមបង្ការ។ កសាងសមត្ថភាពដល់បុគ្គលិក អង្គការមិនមែនរដ្ឋា

ភិបាល និងបុគ្គលិករដ្ឋាភិបាលៈ ការត្រៀមបង្ការគ្រោះមហន្តរាយសហគមន៍ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហគមន៍ គម្រោងស្វែរ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការត្រៀមបង្ការគ្រោះមហន្តរាយសហគមន៍ និងបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

<u>វេទិកាពិភាក្សា</u>

**សំនួរៈ**

១. **លោក ជី បូរ៉េត** នាយកប្រតិបត្តិ សមាគមកុមារ ខេត្តឧត្តរមានជ័យ បានសួរអំពីការវិភាគលើឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ដីកសិកម្ម និងព្រៃឈើ តើសម្បទានសេដ្ឋកិច្ចជះឥទ្ធិពលអ្វីខ្លះដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់? មានព្រះរាជក្រិត្យមួយនៅបន្ទាយឆ្មារ មានសម្បទានសេដ្ឋកិច្ចក្នុងតំបន់នេះ ហើយប្រជាជនធ្វើការឈូសឆាយ និងធ្វើប័ណ្ណកម្មសិទ្ធិ។ តើបញ្ហាទាំងនេះត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ជាតិលើកទី១ ដែរឬទេ?

២. **លោក បញ្ញា** មកពីអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម បានចោទសួរថា តើប្រទេសយើងមានការបំភាយឧស្ម័នកម្រិតណានៅក្នុងការធ្វើសារពើភ័ណ្ឌ?

៣. **លោក វាសនា** មកពីអង្គការសកម្មភាពបំរើកូនខ្មែរ តើការីតាសមានយុទ្ធសាស្ត្របែបណាចំពោះប្រជាជនធ្វើចំណាកស្រុក ដែលបណ្តាលពីបញ្ហាប្រែប្រួលអាកាសធាតុ?

៤. **តំណាងមកពីអង្គការ** AFSC បច្ចុប្បន្នព្រៃឈើកំពុងតែបាត់បង់ តើរដ្ឋាភិបាលមានឆន្ទៈយ៉ាងណាចំពោះការការពារព្រៃឈើ?

**ចម្លើយៈ**

**លោក អ៊ុក ណាវ៉ាន់ៈ** យើងបានគណនាបញ្ចូលទាំងអស់ក្នុងរបាយករណ៍លើកទី១ ដោយមានការសិក្សាស្រាវជ្រាវសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ផ្នែកព្រៃឈើ និងកសិកម្ម។ ដើម្បីគណនាសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ យើងត្រូវដឹងគំរបព្រៃឈើ ប្រភេទឈើ តាមរយៈការធ្វើគណនាជាឡូត៍។ នៅពេលដែលគណនាសរុបទាំងអស់ យើងនឹងដឹងថាប្រទេសកម្ពុជាយើងបំភាយប៉ុណ្ណា និងស្រូបប៉ុណ្ណា ហើយមានវិស័យផ្សេងៗទៀត មានវិស័យឧស្សាហកម្ម ដឹកជញ្ជូន ការរស់នៅសំណល់បូកបញ្ចូលគ្នា នោះយើងនឹងដឹងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់សម្រាប់ឆ្នាំ១៩៩៤។ នៅពេលដែលគណនា ក្នុងឆ្នាំ១៩៩៤ យើងឃើញថា ព្រៃឈើប្រទេសកម្ពុជា មានសមត្ថភាពស្រូបយកឧស្ម័នផ្ទះកញ្ចក់ ជាជាងការបំភាយ ដែលគេឲ្យឈ្មោះថា Net Sink មានន័យថាជាប្រទេសដែលបំភាយតិចជាងការស្រូបយក។ ក្រោយមកទៀតយើងបាន រៀបចំរបាយការណ៍ជាតិលើកទី ២ យកឆ្នាំ ២០១០ ជាគោល នៅពេលដែលយើងបានគណនាយើងឃើញថា ចន្លោះឆ្នាំ ១៩៩៤ និង ឆ្នាំ ២០១០ យើងបានបាត់បង់ព្រៃឈើអស់ច្រើន ដោយបំលែងពីដីព្រៃទៅជាដីកសិកម្ម ជីវភាពប្រជាជន និងការប្រើប្រាស់ថាមពលកើនឡើង។ លទ្ធផលនៃការគណនាក្នុងឆ្នាំ ២០១០ ប្រទេសកម្ពុជាយើងលែងជាប្រទេសស្រូបយក (Net Sink) ទៀតហើយ ហើយប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានការបំភាយច្រើនជាងសមត្ថភាពស្រូបយក ដោយសារយើងបាត់ព្រៃឈើខ្លះ។ របាយការណ៍នេះ ត្រូវបានបញ្ជូនទៅគណៈកម្មការចាត់តាំងរបស់អនុសញ្ញា ដើម្បីធ្វើការពិចារណាសម្រាប់ប្រទេសកម្ពុជា។ ថ្វីត្បិតតែការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ឆ្នាំ២០១០ ប្រទេសកម្ពុជាយើងជាប្រទេសបំភាយក៏ពិតមែន ប៉ុន្តែយើងស្ថិតក្នុងកម្រិតបំភាយតិច ដោយយើងយកទិន្នន័យបំភាយឧស្ម័នផ្ទះកញ្ចក់សរុបមកចែកនឹងចំនួនប្រជាជនសរុប យើងឃើញថា ប្រជាជនកម្ពុជាបំភាយក្នុងម្នាក់ ០,៣តោន ក្នុងមួយឆ្នាំនៃឧស្ម័នកាបូនិចសមមូល។ ឧទាហរណ៍ប្រៀបធៀបនឹងប្រទេសអភិវឌ្ឍន៍ ដែលមានជាង ៣០ប្រទេស រួមមានសហរដ្ឋ

អាមេរិច និងសហគមន៍អឺរ៉ុប ដែលបំភាយពី ៥ទៅ ១០តោន ក្នុងម្នាក់ ហើយសហរដ្ឋអាមេរិចបំភាយម្នាក់ ២០,៥តោន ក្នុងមួយឆ្នាំ។ សព្វថ្ងៃសីតុណ្ហភាពធម្យមរបស់ផែនដីកើនឡើង ០,៧អង្សារសេ ប៉ុន្តែការចរចារអន្តរជាតិ គេបានកំណត់ជាគោលការណ៍សីតុណ្ហភាពជាមធ្យមរបស់ផែនដីមិនគួរឡើងហួស ២ អង្សារសេ ពីព្រោះវានឹងធ្វើឲ្យខូចប្រព័ន្ធអេកូឡូស៊ី ឧទាហរណ៍ មនុស្សយើងមានសីតុណ្ហភាពមធ្យម ៣៦ អង្សារសេ ចំណែកឯផែនដីមាន ១៦,៥ អង្សារសេ នៅពេលដែលកម្តៅឡើង ២ អង្សារសេ នោះ មនុស្សយើងនឹងមានបញ្ហាដែលត្រូវជួបនឹងគ្រូពេទ្យ។ ដើម្បីបង្ការមិនឲ្យកម្តៅផែនដីឡើងលើស ២ អង្សារសេ គេត្រូវគណនាឧស្ម័នផ្ទះកញ្ចក់ប៉ុន្មានប្រភេទ និងធ្វើយ៉ាងណាមិនឲ្យលើសពី ២ អង្សារសេ។ ហេតុនេះហើយទើបគេតម្រូវថា នៅឆ្នាំ ២០២០ ដើម្បីមិនឲ្យសីតុណ្ហភាពផែនដីឡើងលើសពី ២ អង្សារសេ ប្រទេស ឧស្សាហកម្មទាំង ៣៨ ត្រូវកាត់បន្ថយឲ្យបាន ៤០ភាគរយនៃកម្រិតបំភាយឧស្ម័នផ្ទះកញ្ចក់ ប្រៀបនឹងឆ្នាំ ១៩៩០ ប៉ុន្តែក្នុងការចរចារកន្លងគ្មានប្រទេសណាមួយអាចធ្វើបាននោះទេ។ នៅថ្ងៃខាងមុខ សីតុណ្ហភាពមធ្យមរបស់ផែនដីនឹងកើនឡើងលើស ២ អង្សារសេ ពេលនោះពិភពលោកទាំងមូលនឹងជួបប្រទះនឹងគ្រោះមហន្តរាយ។ ដូច្នេះត្រូវធ្វើការគណនាកូតានៃការបំភាយរបស់មនុស្សម្នាក់ៗនៅលើពិភពលោក ថាតើម្នាក់ៗ បំភាយឧស្ម័នផ្ទះកញ្ចក់ប៉ុន្មាន ហើយគេបានគណនាឃើញថា កូតានៃការបំភាយរបស់មនុស្សម្នាក់ៗ មិនឲ្យលើសពី ៥តោន ប្រសិនការបំភាយរបស់មនុស្សម្នាក់ៗលើសពី ៥តោន នោះកម្តៅផែនដីនឹងលើសពី ២ អង្សារសេ។ ដូច្នេះសហរដ្ឋអាមេរិកប្រណែននិងប្រទេសចិនថា សព្វថ្ងៃប្រទេសចិនបំពុលខ្លាំងជាងសហរដ្ឋអាមេរិកទៅទៀត ប៉ុន្តែមានឱកាសក្នុងការអនុវត្តបន្តទៀតបាន នេះគឺដោយសារតែពិធីសារក្យូតូដែលបានចែកប្រទេសក្នុងពិភពលោកជាពីរ គឺប្រទេសអ្នកមាន និងប្រទេសអ្នកក្រ ក្នុងនោះរាប់បញ្ចូលចិនផងដែរ ដោយសារតែប្រជាជនចិនម្នាក់បំភាយ ៣តោន ក្នុងមួយឆ្នាំ ដូច្នេះនៅពេលដែលគេគិតកូតាប្រហែល ៥តោន ដែលកម្រិតសម្រាប់ការចរចារ ហេតុដូចនេះ ទើបធ្វើឲ្យអាមេរិកដើរចេញពីការចរចារពិធីសារក្យូតូ ឬមួយមិនស្ថិតនៅក្រោមច្បាប់នៃពិធីសារនេះ។ សព្វថ្ងៃគេចរចារដោយផ្អែកលើគោលការណ៍បែបនេះ ប្រទេសកម្ពុជាយើងមានបំភាយតិចតួច និងមិនមែនជាអ្នកធ្វើឲ្យអាកាសធាតុប្រែប្រួលទេ តែយើងជាអ្នករងគ្រោះ។ ហេតុនេះហើយទើបយើងតែងតែអំពាវនាវឲ្យប្រទេសអ្នកមានគួរតែមានសំណងផ្នែកហិរញ្ញវត្ថុ គាំទ្រផ្នែកបច្ចេកទេស ដែលយើងសូមឲ្យជំនួយនេះដោយមិនមានសំណង។

REDD ជាគោលគំនិតល្អក្នុងការថែរក្សាព្រៃឈើឲ្យគង់ ហើយគណនាបរិមាណដែលព្រៃឈើអាចស្រូចយកកាបូនបានបរិមាណដែលព្រៃឈើស្រូប វាគឺជាឥណទានដែលអាចដូរនឹងថវិកាបាន។ REDD មានដើមកំណើតក្នុងឆ្នាំ ២០០៧ ដែលប្រទេសកម្ពុជាសព្វថ្ងៃកំពុងអនុវត្តគម្រោងចំនួន ២ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងឧត្តរមានជ័យ ទទួលបានថវិកាចំនួនប្រមាណ ៥០ម៉ឺនដុល្លារ សម្រាប់រយៈពេល ៥ឆ្នាំ តាមរយៈគម្រោងទីផ្សារស្ម័គ្រចិត្ត និងគម្រោង REDD មួយទៀតអនុវត្តដោយក្រសួងបរិស្ថាន ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងខេត្តពោធិសាត់ មកដល់សព្វថ្ងៃយើងទទួលថវិកាបាន ៦លានដុល្លារអាមេរិក ហើយថវិកានេះបានចូលទៅក្នុងធនាគារជាតិរួចហើយ នេះជាប្រាក់កក់ទេ។ REDD នេះនឹងដំណើរការរបៀបទីផ្សារស្ម័គ្រចិត្តដដែល ដោយសារតែពុំទាន់មានគោលការណ៍ទីផ្សារទេ គោលការណ៍ទាំងនេះត្រូវផ្អែកលើកិច្ចប្រជុំកំពូល ដែលយើងមានការខកចិត្តចំពោះកិច្ចប្រជុំនៅទីក្រុងដូហា ដោយសារ REDD ពុំមានឥទ្ធិពល ដោយគេបានសង្ឃឹមថា ព្រៃឈើក្នុងពិភពលោកនឹងត្រូវបានរក្សា ដោយមានច្បាប់ទីផ្សារដែលមិនមែនជាទីផ្សារស្ម័គ្រចិត្ត។ ក្នុងកិច្ចប្រជុំលើកទី១៤ ប្រទេសប៉េរូ មានឧទ្យានជាតិយ៉ាសានី មានជីវចម្រុះច្រើនជាងសហរដ្ឋអាមេរិកទាំងមូល ហើយប្រទេសប៉េរូ បានរកឃើញប្រេងកាតនៅក្នុងឧទ្យានជាតិនេះ គេអាចទាញយកចំណូលពីប្រេងកាតបានយ៉ាងច្រើន ប្រទេសប៉េរូយល់ព្រមរក្សាឧទ្យានជាតិនេះឲ្យគង់ ជាថ្នូរនឹងលុយ ៣០០លានដុល្លារ ក្នុងមួយឆ្នាំ ប៉ុន្តែក្នុងកិច្ចប្រជុំនេះពុំមាននរណាហ៊ានផ្តល់លុយដល់ប្រទេសប៉េរូទេ នេះគេហៅថា បរាជ័យទីផ្សារ (Market Failure) ដោយសារតែការអភិរក្សមានតម្លៃតិចជាងអភិវឌ្ឍន៍។ ប្រទេសកម្ពុជា រដ្ឋាភិបាលបានផ្តល់អាទិភាពលើការអភិ

វឌ្ឍន៍ដែរដោយសារប្រជាជនកើនឡើងមានតម្រូវការអគ្គិសនីដើម្បីការរស់នៅសមស្របដែលប្រទេសកម្ពុជាយើងមានសក្តានុពលក្នុងការអភិវឌ្ឍវារីអគ្គិសនី ស្ថិតក្នុងតំបន់ភ្នំសំបូរព្រៃឈើច្រើន ដើម្បីធានាសុវត្ថិភាពថាមពលសម្រាប់ទាក់ទាញវិនិយោគទុន ដូច្នេះយើងត្រូវលះបង់ព្រៃឈើខ្លះ ដែលព្រៃទាំងនោះស្ថិតក្នុងតំបន់ការពារធម្មជាតិ។ រដ្ឋាភិបាលបានពិចារណាថ្លឹងថ្លែងមុននឹងផ្តល់សម្បទាន ឧទាហរណ៍ ការរកឃើញរ៉ែទីតាញ៉ូម ប៉ុន្តែផលប៉ះពាល់ពីការវិនិយោគនេះធំ ដូចនេះរដ្ឋាភិបាលសម្រេចមិនផ្តល់សម្បទានរ៉ែ។ ដោយឡែកយើងត្រូវធ្វើ វិនិយោគចំពោះដំណាំកសិឧស្សាហកម្ម ដែលយើងទាញយកចំណូលពីពន្ធ និងផ្តល់ការងារដល់ប្រជាជនខ្មែរ។

REDD វាអាស្រ័យនឹងទីផ្សារស្ម័គ្រចិត្តអន្តរជាតិ។ ប្រសិនបើគ្មានទីផ្សារអន្តរជាតិស្ម័គ្រចិត្រនោះទេ ព្រៃឈើលើពិភពលោកនឹងបាត់បង់ ដោយសារគ្មាននរណាផ្តល់ថវិកាសម្រាប់ថែរក្សាព្រៃឈើឲ្យបានគង់វង្ស។ នៅក្នុងការចរចារថ្មីៗ គេបាននិយាយអំពី REDD ថាគឺជាបរាជ័យទីផ្សារ។

**លោក សុខ សាខន** ៖ ការីតាសបានអនុវត្តរួចមកហើយនូវយុទ្ធសាស្រ្តកាត់បន្ថយការធ្វើចំណាកស្រុក ហើយយើងមានសកម្មភាព ការស្តារឡើងវិញនូវចំណាកស្រុកដោយខុសច្បាប់ យើងមានគម្រោងសម្រាប់ស្តារឡើងវិញ ក្នុងនោះមានសកម្មភាព២ធំ ទី១. អភិវឌ្ឍន៍សហគមន៍ ទី២. អភិវឌ្ឍន៍យុវជន។ អភិវឌ្ឍន៍សហគមន៍ យើងបានជម្រុញលើកទឹកចិត្តការដាំដុះ បង្កើនប្រាក់ចំណូលតាមរយៈការចិញ្ចឹមសត្វ សិប្បកម្មតាមផ្ទះ ជម្រុញផលិតផលកសិកម្ម ផ្តល់ជំនួយបច្ចេកទេស ដើម្បីទទួលផលបានច្រើន និងលើកកម្ពស់មុខរបរ ដោយមានមណ្ឌលផ្តល់ជំនាញវិជ្ជាជីវដល់យុវជន អាចឲ្យយុវជនមានការងារធ្វើ។ យើងនឹងរៀបចំមជ្ឈមណ្ឌលសម្រាប់ស្តារលទ្ធភាព របស់ជនដែលរងគ្រោះពីចំណាកស្រុក ដើម្បីឲ្យគាត់អាចទទួលជំនាញបច្ចេកទេស។

៤. ណែនាំអំពីការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការគ្រប់គ្រង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

**លោក តឹក វណ្ណារ៉ា** នាយកប្រតិបត្តិរង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានណែនាំអំពីការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការគ្រប់គ្រង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដើម្បីជំនួសគណៈកម្មការគ្រប់គ្រង ៣រូប លោកស្រី ប៉ុក បញ្ញាវិចិត្រ លោកស្រី ព្រី ផល្លីភួង និង កញ្ញា សែន ជឿនសាហ៊ី ដែលចប់អណត្តិ។ បេក្ខជនឈរឈ្មោះបោះឆ្នោតមាន ៧ រូប រួមមាន ១. លោក ស៊ុន សុងហាក់ ២.លោកស្រី ព្រី ផល្លីភួង ៣. លោក ងិន សៅរ័ត្ន ៤. លោកស្រី កែ សុខនី ៥. លោក ឯក ចំរើន ៦. លោក កុល សារ៉ាន់ ៧. លោក ស៊ុន យូរ៉ា។ លោកក៏បានណែនាំឲ្យអ្នកបោះឆ្នោតធ្វើការពិនិត្យប្រវត្តិរូបឲ្យបានត្រឹមត្រូវមុននឹងបោះឆ្នោត តំណាងអង្គការសមាជិកអាចបោះឆ្នោតបានតែមួយសម្លេងទេ និងមានអ្នកស្ម័គ្រចិត្តដើម្បីធ្វើការរាប់សន្លឹកឆ្នោតដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ និងត្រឹមត្រូវ។

<u>ការប្រកាសលទ្ធផលពីការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិកាគ្រប់គ្រង</u>

**លោក តឹក វណ្ណារ៉ា** ប្រកាសលទ្ធផលនៃសម្លេងឆ្នោតមាន ១. លោក ស៊ុន សុងហាក់ (២៧សម្លេង) ២. លោកស្រី ព្រី ផល្លីភួង (៣៥សម្លេង) ៣. លោក ងិន សៅរ័ត្ន (២៣សម្លេង) ៤. លោកស្រី កែ សុខនី (២០សម្លេង) ៥. លោក ឯក ចំរើន (១៣សម្លេង) ៦. លោក កុយ សារ៉ាន់ (១៤សម្លេង) និង ៧. លោក ស៊ុន យូរ៉ា (៣៦សម្លេង)។ ដូចនេះ ១. លោក ស៊ុន យូរ៉ា (៣៦សម្លេង) ២. លោកស្រី ព្រី ផល្លីភួង (៣៥សម្លេង) និង ៣. លោក ស៊ុន សុងហាក់ (២៧សម្លេង)។ សម្លេងឆ្នោតសរុបមានចំនួន ៥៧សន្លឹក អនុប្បវាទ ១សន្លឹក ដូច្នេះសន្លឹកឆ្នោតបានការមាន ៥៦សន្លឹក។

<u>សេចក្តីថ្លែងអំណរគុណចំពោះសមាជិកគណៈកម្មាធិការគ្រប់គ្រង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលបានចប់អាណត្តិ និង កិច្ចស្វាគមន៍ចំពោះសមាជិកថ្មី</u>

**លោក ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានស្វាគមន៍ចំពោះតំណាងអង្គការដែលបានជាប់ឆ្នោតថ្មី។ ឆ្លៀតឱកាសនេះដែរ លោកក៏បានថ្លែងអំណរគុណចំពោះ លោក លោកស្រី ដែលបានចប់អាណត្តិ ក្នុងនោះមានលោកស្រី ប៉ុក បញ្ញាវិចិត្រ រយៈពេល ៤ឆ្នាំ ដែលពីមុនលោកស្រីធ្វើការនៅអង្គការលូថេរ៉ានបំរើពិភពលោក (LWF) ក្រោយមកលោកស្រីបានក្លាយមកជានាយកប្រតិបត្តិអង្គការ CWCC និងបានជាប់ឆ្នោតជាប្រធានគណៈកម្មាធិការគ្រប់គ្រង។ លោក ឈិត សំអាត ក៏បានជូននូវវត្ថុអនុស្សាវរីយ៍ និង លិខិតសរសើរ សម្រាប់ថ្លែងអំណរគុណចំពោះកិច្ចខំប្រឹងប្រែងរបស់លោកស្រី ពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ បច្ចុប្បន្នយើងមានសមាជិកគណៈកម្មាធិការ ៧រូប ក្នុងនោះនឹងត្រូវបោះឆ្នោតជ្រើសរើស ប្រធានគណៈកម្មាធិការគ្រប់គ្រងម្នាក់ផងដែរ។

៦. ដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

**លោក ប៉ូច សុវណ្ណឌី** អគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ បានលើចំនុចសំខាន់ ២ ទាក់ទងនឹងឋានានុក្រម និងតួនាទីរបស់គោលនយោបាយ ផែនការ និងកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជាព្រមទាំងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨។ មុននឹងរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ចាំបាច់ត្រូវមានកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ពេលនោះកម្មវិធីគោលនយោបាយត្រូវបង្ហាញក្នុងកិច្ចប្រជុំទី១ ជូនសមាជិកសភា ហើយនៅពេលរាជរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមដំណើរការ បានរៀបចំបំលែងកម្មវិធីគោលនយោបាយនេះ ឲ្យទៅជារបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅពេលដែលយើងបានបង្កើតផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិហើយ ក្នុងនោះមានគោលនយោបាយអាទិភាពសំខាន់ៗ ដែលបានបញ្ចូលក្នុងនេះ។ របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺ យុទ្ធសាស្រ្តចតុកោណ ក្នុងនោះមានយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ១ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ ហើយអណត្តិក្រោយនឹងរៀបចំយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣។ ដើម្បីអនុវត្តយុទ្ធសាស្រ្តចតុកោណ រាជរដ្ឋាភិបាលត្រូវរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ហើយកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ នឹងរួមចំណែកក្នុងការរៀបចំផែនការយុទ្ធសាស្រ្តថវិកាជាតិ ដើម្បីដំណើរការការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ។ បន្ទាប់ពីរៀបចំផែនការអភិវឌ្ឍន៍ជាតិនេះហើយ បណ្តាគោលនយោបាយតាមវិស័យផ្សេងៗ មានតែគោលនយោបាយធំៗប៉ុណ្ណោះ និងបន្តរៀបចំគោលនយោបាយលម្អិតតាមវិស័យ។

ដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ផ្អែកលើយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលហើយ ដោយសារតែដំណើរការនៃផែនការមួយត្រូវបញ្ចប់ ដូច្នេះត្រូវរៀបចំផែនការថ្មី។ ទោះបីជា ក្រសួងផែនការមានតួនាទីរបស់ខ្លួនក្នុងការរៀបចំផែនការជាតិក៏ដោយ មុននឹងចាប់ផ្តើមត្រូវតែសុំគោលការណ៍ពីរាជរដ្ឋាភិបាលជាមុនសិន ដែលគោលការណ៍នេះជាឯកសារយោងសម្រាប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីសហការជាមួយក្រសួងផែនការ។ នៅពេលបានគោលការណ៍ហើយ នឹងបង្ហាញដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីណែនាំអំពីការរៀបចំធាតុចូលសម្រាប់ផ្ញើជូនក្រសួងផែនការ ហើយក្រសួងផែនការនឹងរៀបចំជាសេចក្តីព្រាងផែនការ នៅពេលដែលក្រសួងស្ថាប័នបានផ្ញើជូននូវធាតុចូល។ នៅពេលរៀបចំសេចក្តីព្រាងហើយ ជាដំណាក់នៃការពិភាក្សាដោយផ្ញើសេចក្តីព្រាងជូនស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ពិនិត្យ ថាតើធាតុចូលដែលបានរៀបចំក្នុងសេចក្តីព្រាងផែនការនេះ បានដាក់ចូលហើយឬនៅ និងពិនិត្យ និងផ្តល់អនុសាសន៍។ ការពិនិត្យមើល និងផ្តល់អនុសាសន៍ពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល គឺស្ថិតក្នុងដំណាក់កាលនេះហើយ ដែលធាតុចូលពីអង្គការសង្គមស៊ីវិល ត្រូវតែរួមចំណែកធ្វើការពិភាក្សាតាមរយៈយន្តការក្រុម

ការងារចម្រុះ។ ចំពោះបញ្ហាអន្តរវិស័យ ឧទាហរណ៍ បញ្ហាប្រែប្រួលអាកាសធាតុ ពុំមានក្រុមការងារចម្រុះទេ ដូចនេះ អង្គការ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា អាចធ្វើការពិភាក្សាធាតុចូល និងអនុសាសន៍ផ្សេងៗ ដោយពិភាក្សាផ្ទាល់ជាមួយក្រសួងស្ថាប័ន ដែលសម្របសម្រួលលើបញ្ហាប្រែប្រួលអាកាសធាតុ ដែលមានក្រសួងបរិស្ថានទទួលបន្ទុក។ នៅពេលដែលធាតុចូលត្រូវបានយល់ព្រមដាក់ចូលដោយក្រសួង នោះក្រសួងផែនការនឹងពិនិត្យមើល មុននឹងដាក់បញ្ចូលក្នុងផែនការជាតិ។ បន្ទាប់ពីទទួលបានធាតុចូល និងអនុសាសន៍រួចមក កិច្ចប្រជុំពិភាក្សានឹងត្រូវបានរៀបចំឡើងតាមរយៈ ការបង្ហាញក្រៅផ្លូវការជាដំបូង និងមានការបង្ហាញជាទូទៅក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យមើលសេចក្តីព្រាង ដែលកិច្ចប្រជុំនេះមាន ២ដំណាក់កាល ក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ។ បន្ទាប់មកមានកិច្ចប្រជុំមួយផ្សេងទៀតរវាងក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មការជាតិនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័ន ៤ ទទួលបន្ទុកហិរញ្ញវត្ថុ ទទួលជំនួយដើម្បីដំណើរការអភិវឌ្ឍន៍ បន្ទាប់មក សេចក្តីព្រាងចុងក្រោយនឹងត្រូវផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រី។ នៅពេលសេចក្តីព្រាងបានផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រីហើយ នឹងមិនបានបញ្ចូលភ្លាមក្នុងកិច្ចប្រជុំពេញអង្គរបស់ទីស្តីការគណៈរដ្ឋមន្ត្រីទេ ប៉ុន្តែនឹងមានកិច្ចប្រជុំបីលើកបន្ថែមទៀតនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រីនោះ ក្នុងនោះមានកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ រួមទាំង ក្រុមប្រឹក្សាអក្សរសាស្ត្រ ដើម្បីពិនិត្យមើលលើអក្សរសាស្ត្រ ច្បាប់ និងខ្លឹមសារសេដ្ឋកិច្ច សង្គមកិច្ច។ បន្ទាប់ពីទទួលបានអនុសាសន៍ពីកិច្ចប្រជុំនេះហើយ យកសេចក្តីព្រាងមកកែសម្រួល និងមានកិច្ចប្រជុំអន្តរក្រសួងម្តងទៀត ដែលកិច្ចប្រជុំលើកនេះដឹកនាំកិច្ចប្រជុំដោយអគ្គលេខាធិការរាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់មកទៀត នឹងមានកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដែលដឹកនាំផ្ទាល់ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ នៅពេលកែសម្រួលចប់សព្វគ្រប់តាមយោបល់រួចហើយ នឹងចូលដល់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ដោយសារតែផែនការនេះមានកម្រិតច្បាប់ មានន័យថា នៅពេលដែលឯកសារនេះត្រូវបានអនុម័តរួចហើយ គឺត្រូវតែអនុវត្ត ដូច្នេះអាចបញ្ជាក់បានថាមានកម្រិតស្មើនឹងច្បាប់ ដូច្នេះ ឯកសារនេះនឹងត្រូវទទួលការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា តាមរយៈការប្រជុំរដ្ឋសភាព បន្ទាប់មកអនុម័តពីព្រឹទ្ធសភា ហើយចុងក្រោយឯកសារនេះ នឹងត្រូវមានការឡាយព្រហស្តលេខាពីព្រះរាជក្រមដើម្បីដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ទើបផែនការនេះ អាចដាក់ឲ្យអនុវត្តពេលលេញបាន។ បន្ទាប់ពីឡាយព្រហស្តលេខារួចហើយ ទើបធ្វើការបោះពុម្ព និងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅថ្នាក់ជាតិក្រោមអធិបតីភាពរបស់ប្រមុខរដ្ឋាភិបាល ប្រសិនបើថវិការគ្រប់គ្រាន់ យើងនឹងធ្វើការផ្សព្វផ្សាយនៅគ្រប់ខេត្ត ប្រសិនបើថវិកាមិនគ្រប់គ្រាន់នឹងមានតែការផ្សព្វផ្សាយថ្នាក់តំបន់ប៉ុណ្ណោះ។

### ៧. ការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

**លោកស្រី ចាន់ សុខយ៉េង** ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានបង្ហាញពីការចូលរួមចំណែករបស់សង្គមស៊ីវិល ក្នុងការរៀបចំ និងការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយបានលើកឡើងពីសារៈសំខាន់នៃការចូលរួមរបស់សង្គមស៊ីវិល ដែលបានបំពេញបន្ថែមជាមួយរដ្ឋាភិបាលក្នុងការរៀបចំសេចក្តីព្រាងផែនការជាតិ តាមរយៈការប្រមូលគំនិត និងព័ត៌មានពីមូលដ្ឋាន ជួយឲ្យប្រព័ន្ធរដ្ឋាភិបាលកាន់តែឆ្លើយតបនឹងតម្រូវការប្រជាជនកម្ពុជា និងជួយផ្សព្វផ្សាយផែនការជាតិកាន់តែទូលំទូលាយ។ អំឡុងពេលអនុវត្តផែនការជាតិ អង្គការសង្គមស៊ីវិលអាចចូលរួមផ្តល់គំនិតពីមូលដ្ឋាន ក្នុងការអនុវត្តគោលនយោបាយ តាមដានវឌ្ឍនភាពតាមរយៈការអង្កេតការពេញចិត្តរបស់ប្រជាពលរដ្ឋ ចូលរួមអនុវត្តកម្មវិធីឲ្យស្របនឹងអាទិភាពផែនការជាតិ និងតស៊ូមតិដើម្បីឲ្យការអនុវត្តគោលនយោបាយក្នុងការកាត់បន្ថយភាពក្រីក្រ។ នៅពេលដែលក្រសួងផែនការបានផ្ញើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ជូនសង្គមស៊ីវិលធ្វើការផ្តល់យោបល់ គម្រោងគោលនយោបាយអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការសង្គមស៊ីវិលតាមវិស័យចំនួន ១៨ បានចូលរួមយ៉ាងផុស

ផុលក្នុងការផ្តល់មតិយោបល់។ ក្នុងចំណោម ១៨ វិស័យ មតិយោបល់លើ ១៤ វិស័យ (៧៧,៧៧ភាគរយ) និង ៦៥ (១៧,៣៣ភាគរយ) នៃ ៣៧៥ មតិយោបល់ ត្រូវបានដាក់បញ្ចូលក្នុង ផយអជ បច្ចុប្បន្នកម្ម។ ក្នុងដំណើរការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងយន្តការពិគ្រោះយោបល់ តាមរយៈក្រុមការងារបច្ចេកទេស នៅមានកម្រិត។ សេចក្តីព្រាង ផយអជ បច្ចុប្បន្នកម្មដែលបានផ្ញើជូនភាគីពាក់ព័ន្ធ ត្រូវបានពន្យារ និងផ្តល់រយៈពេល ១៥ថ្ងៃ សម្រាប់ផ្តល់យោបល់។ មានអង្គការសង្គមស៊ីវិលតាមវិស័យមួយចំនួន ដែលបានដាក់ជូនមតិយោបល់លើរបាយការណ៍ពាក់កណ្តាលអណត្តិនៃ ផយអជ បច្ចុប្បន្នកម្ម ជូនប្រធានក្រុមការងារបច្ចេកទេសនៃក្រសួងសាមី ក្នុងខែតុលា ឆ្នាំ២០១១។ សង្គមស៊ីវិលតាមវិស័យចំនួន ២១ បានតាមដានការអនុវត្ត ផយអជ និងសូចនាករតាមដានរួម (JMIs) ដោយបានផលិតឯកសារគោលជំហរពិនិត្យតាមដានវឌ្ឍនភាពនៃសូចនាករតាមដានរួម ការអនុវត្ត ផអយជ បច្ចុប្បន្នកម្ម និងបញ្ហាផ្សេងៗ ក្នុងឆ្នាំ២០១០-២០១២ ក្រោមការសម្របសម្រួលរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា CCC និង MEDiCAM ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកបណ្តាញ និងអ្នកពាក់ព័ន្ធ។ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ចំនួន ១៣៧ បានពិគ្រោះយោបល់នៅថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយឯកសារគោលជំហរជាផ្លូវការ និងចេញសេចក្តីថ្លែងការរួមស្តីពីមតិយោបល់ និងសំណូមពររបស់សង្គមស៊ីវិល។ ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិល ចំនួន២០០ច្បាប់ ត្រូវបានដាក់ជូនរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលបានចូលរួមកិច្ចប្រជុំ GDCC លើកទី១៩ និងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីប្រព័ន្ធផ្សព្វផ្សាយ និងដៃគូអភិវឌ្ឍន៍ ពិសេសវិស័យដីធ្លី។ ទោះបីជាឯកសារគោលជំហរតាមដានការអនុវត្តផែនការជាតិ ត្រូវបានផលិតដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលតាមវិស័យក៏ដោយ ក៏ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលនេះ មិនបានគ្របដណ្តប់គ្រប់វិស័យទេ ដូចជា ប្រឆាំងអំពើពុករលួយ យេនឌ័រ និងអប់រំក្រៅប្រព័ន្ធ។ សមត្ថភាពរបស់អង្គការស៊ីវិលក្នុងការតាមដានគោលនយោបាយ នៅមានកម្រិត។ ឯកសារត្រួតពិនិត្យតាមដាន ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្ម និងកែសម្រួលជាប្រចាំ ដើម្បីធានាថា បញ្ហា និងអនុសាសន៍ដែលបានលើកឡើងនៅតែមានសុពលភាព។ ឯកសារគោលជំហរតាមវិស័យ បានរៀបចំឡើងដោយផ្អែកលើព័ត៌មានតាមរយៈការសង្កេត និងឯកសារយោងនានារបស់អ្នកសរសេរ ដែលមិនឆ្លុះបញ្ចាំងក្នុងប្រភពព័ត៌មានដែលមិនបានចេញផ្សាយជាសាធារណៈ។ សម្រាប់ដំណើរការរៀបចំ ផយអជ ឆ្នាំ២០១៤-២០១៨ សង្គមស៊ីវិលនឹងបន្តរួមចំណែកជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការផ្តល់មតិយោបល់សម្រាប់ជាធាតុចូលក្នុងការៀបចំ ផយអជ ឆ្នាំ២០១៤-២០១៨ ដែលចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០១៣។ អង្គការសង្គមស៊ីវិលសង្ឃឹមយ៉ាងមុតមាំថា ក្រសួងផែនការនឹងបន្តផ្តល់ឱកាសពិនិត្យ ផ្តល់យោបល់លើ ផយអជ ឆ្នាំ២០១៤-២០១៨ ជាមួយពេលវេលាកាន់តែសមស្រប។ អង្គការសង្គមស៊ីវិលតាមវិស័យ និងសមាជិកបណ្តាញ អាចចូលរួមផ្តល់យោបល់តាមរយៈកិច្ចប្រជុំជាមួយក្រសួងស្ថាប័ន សាមី កិច្ចប្រជុំក្រុមការងារបច្ចេកទេស ការផលិតឯកសារមតិយោបល់តាមវិស័យលើសេចក្តីព្រាង ផយអជ ក្រោមការសម្របសម្រួលរបស់ NGO Forum CCC និង MEDiCAM។

<u>វេទិកាពិភាក្សា</u>

**សំណួរ:**

១. **លោកស្រី កែវ ណាវ៉ាន់:** តើមានមូលហេតុអ្វីខ្លះ ដែលរដ្ឋាភិបាលមិនអាចដាក់បញ្ចូលអនុសាសន៍ផ្សេងៗ របស់អង្គការមិនមែនរដ្ឋាភិបាល?

២. **លោក ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា៖ តើនៅក្នុងយន្តការរបស់រាជរដ្ឋាភិបាលមាននីតិវិធី និងមធ្យោបាយ ក្នុងការត្រួតពិនិត្យតាមដានការរីកចំរើននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយរបៀបណា? តើមានរបាយការណ៍ជាសាធារណៈដើម្បីចែកសង្គមស៊ីវិល ឬសាធារណៈអំពីលទ្ធផលនៃការតាមដាននេះទេ?

**ចម្លើយៈ**

**លោក ប៉ូច សុវណ្ណឌី:** បណ្តាអនុសាសន៍ និងធាតុចូលពីអង្គការមិនមែនរដ្ឋាភិបាល ត្រូវដាក់ចូលតាមក្រុមការងារបច្ចេកទេសតាមវិស័យ។ ចំពោះការសម្រេចដាក់បញ្ចូល គឺអាស្រ័យលើក្រសួងតាមវិស័យ បញ្ហាមួយចំនួនមិនត្រូវបានដាក់បញ្ចូល អាចមកពីបញ្ហានោះជាបញ្ហារសើប ឬ បញ្ហាមិនសូវសំខាន់។ ក្រសួងផែនការទទួលបន្ទុកដាក់បញ្ចូលធាតុចូល ហើយក្រសួងផែនការ មានសិទ្ធិក្នុងការសង្ខេបធាតុចូល ដោយរក្សាខ្លឹមសារដដែល ដើម្បីធ្វើយ៉ាងណាឲ្យមានតុល្យភាព។ ទាក់ទងនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គឺមានយន្តការបញ្ជាក់យ៉ាងច្បាស់ក្នុងជំពូកទី៦ ដែលមាន ២ដំណាក់កាល។ ការតាមដានត្រួតពិនិត្យ វាយតម្លៃ ដែលធ្វើឡើងដោយក្រសួងសាមី ដោយឡែក ការវាយតម្លៃលើសូចនាករ មានជារួមចំនួន ៦៣ គ្រប់វិស័យទាំងអស់។ ការតាមដានលើការសម្រេចបានលើសូចនាករទាំង ៦៣ គឺជាការទទួលខុសត្រូវរបស់ក្រសួងផែនការ។ ដោយមានការលំបាកក្នុងរៀបចំផែនការយុទ្ធសាស្ត្រចាស់ រដ្ឋាភិបាលក៏សម្រេចធ្វើបច្ចុប្បន្នកម្មឲ្យទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣។ យើងមិនបានរៀបចំធ្វើការវាយតម្លៃលើផែនការយុទ្ធសាស្ត្រពាក់កណ្តាលអណត្តិ។ ក្រោយពេលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានបញ្ចប់ រដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយទៅតាមតំបន់និមួយៗ ដែលក្នុងមួយតំបន់មាន៦ខេត្ត។

៨. សេចក្តីសង្ខេបនៃកិច្ចប្រជុំ និងបិទកិច្ចប្រជុំ

**លោកស្រី ប៉ុក បញ្ញាវិចិត្រ** ប្រធានអង្គប្រជុំ បានបូកសរុបអង្គប្រជុំ ដែលកិច្ចប្រជុំបានលើកឡើងពីការពិភាក្សាអំពីកិច្ចចរចារក្នុង COP18 ហើយការពិភាក្សាស្តីពីការប្រែប្រួលអាកាសធាតុនូវមិនទាន់មានពេលគ្រប់គ្រាន់នៅឡើយ។ ចំពោះដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏នៅមានការខ្វះខាត ដូចជា ផ្នែកយេនឌ័រ ដែលរួមបញ្ចូលគ្រប់វិស័យទាំងអស់ និងការប្រឆាំងនឹងអំពើពុករលួយ។ NGOF ខ្លួនឯងក៏ត្រូវតែមានទម្រង់មួយសម្រាប់ឲ្យមានការបញ្ជ្រាបយេនឌ័រនៅក្នុងធាតុចូលសម្រាប់ដាក់ជូនរដ្ឋាភិបាលផងដែរ។ លោកស្រីក៏បានថ្លែងអំណរគុណចំពោះសមាជិក-សមាជិកា ដែលបានចូលរួមក្នុងកិច្ចប្រជុំក្នុងថ្ងៃនេះ និងប្រកាសបិទអង្គប្រជុំ។

- ចប់ -